# ថ្ងៃមិនរះ

ខ្ញុំឈរនៅមុខផ្សារ សម្លឹងរកម៉ូយ។ ថ្ងៃជិតត្រង់ហើយ នៅមិនទាន់រកបានម្នាក់។ ឯអាសុខនិង អាម៉ៅ ផាក់គ្នាលេង អត់ខ្វល់អីសោះ។ អត់មានមនុស្សជិះស៊ីក្លូ ក៏វាមិនអើពើដែរ។ ពួកវានៅខ្លួនមួយ គឺអីចឹងហើយ មិនដូចខ្ញុំមានកូនប្រពន្ធក្នុងបន្ទុក។ អាសុខដើរមកក្បែរខ្ញុំ ហើយសួរ៖

- ម៉េចហើយពូ? គិតអី?

- អត់ទេ...

- បើអត់ ម៉េចក៏ឈរផ្ទឹងអីចឹង?

ខ្ញុំអត់ឆ្លើយនឹងវា ខ្ញុំសួរវារឿងផ្សេងវិញ៖

- ម៉េច! អ្ហែងថ្ងៃនេះមិនទៅចាក់ឆ្នោតទេអី?

- ចាក់អី! បើយប់មិញលេងបៀចាញ់អស់ហើយ។

- អ្ហែងល្មមចេះសន្សំប្រាក់ទុកដាក់ខ្លះទៅ។

- ពូអើយ! សន្សំអី? បើមាន វាមានយូរហើយ។

- អើ! អ្ហែងចង់ធ្វើអី ធ្វើទៅ! កុំតែមកខ្ចីប្រាក់អញ អញអត់មានប្រាក់ឲ្យខ្ចីទេ។

- និយាយដូចដឹងអីចឹងពូ (អាសុខវាញញឹម យកដៃមកឱបស្មាខ្ញុំ)។

- អ្ហែងស្មានអញមិនដឹងអ្ហេ៎? អញស្គាល់ក្រយៅអ្ហែងច្បាស់ណាស់។

- ពូ! (អាសុខច្របាច់ស្មាខ្ញុំថ្នមៗ)

- មិនបាច់មកសៀសសៃឲ្យអញទេ (ខ្ញុំកៀសដៃវាចេញ) អញគ្មានលុយឲ្យទេ។

- ពូ! កុំធ្វើអីចឹង... តែប្រាំពាន់តើ។

- ថាអត់គឺអត់ហើយ! តាំងពីព្រលឹម រកម៉ូយមិនទាន់បានផង។

- សូមពូប្រណី... អភ័យទោសម្តង... (អាសុខវាច្រៀងដាក់ខ្ញុំ)

ខ្ញុំស្ទុះដេញធាក់វា វាគេចហើយសើចកក្អឹក។

- អ្ហែងលេងមិនស្គាល់ចាស់ទុំ អ្ហែងចង់ធ្លាក់នរកអ្ហែស? (ខ្ញុំខឹងស្រែកជេរវា)

- ចាស់ឯណា? មិនទាន់ចាស់ទេ នៅខ្ចីសោះហ្នឹងណាំ...

ខ្ញុំខឹង ដេញធាក់វាម្តងទៀត។ វារត់បណ្តើរ សើចបណ្តើរ។ ខ្ញុំហួសចិត្តនឹងអាក្មេងមិនទាន់បាត់ធុំក្លិនទឹកដោះនេះ។ ពេលនោះមានស្រីម្នាក់កាន់កន្ត្រកដើរមករកខ្ញុំហើយសួរថា៖

- ពូស៊ីក្លូ ទៅឬអត់?

- បាទ ទៅ! ទៅ!

ខ្ញុំជួយយូរកន្ត្រកម៉ូយដាក់ស៊ីក្លូ។

ខ្ញុំដឹកភ្ញៀវតម្រង់ទៅផ្ទះរបស់គេ។ ផ្ទះគេជាវីឡាធំណាស់ មានឡានបីចតនៅខាងក្នុង។ ហេតុអ្វីគេមានសំណាងអ្វីម្ល៉េះ (ខ្ញុំនឹកក្នុងចិត្ត)? កាលពីមុនគាត់នៅផ្ទះល្វែងទេ ខានឃើញតែពីរឆ្នាំ សោះ គាត់មានវីឡា។ ឯខ្ញុំធាក់ស៊ីក្លូអស់ជាងម្ភៃឆ្នាំហើយ នៅតែដដែល។ ខ្ញុំត្រឡប់មកផ្សារវិញ។ ធាក់បណ្តើរ គិតបណ្តើរ "តើខ្ញុំមានវាសនាបានផ្ទះដូចគេនៅទេ? ហ៊ឺ! ទោះយល់សប្តិ ក៏មិនឃើញ ដែរ"។

ថ្ងៃត្រង់ ខ្ញុំបាយជុំជាមួយប្រពន្ធកូន។ យើងអង្គុយលើគ្រែរនាប ហើយហូបបាយទាំងអស់គ្នា។ ខ្ញុំសម្លឹងមើលកូនៗ ដែលប្រញ៉ាយគ្នាដណ្តើមម្ហូប។ ម្ហូបរបស់យើងមិនមានអីពិសេសទេ មានតែត្រី អាំងពីរជ្រលក់ជាមួយទឹកត្រី។ ខ្ញុំមើលកូនៗ អាណិតពួកគេណាស់ មិនគួរមកកើតជាមួយនឹងឪពុក ម្តាយក្របែបនេះសោះ តើអនាគតរបស់ពួកគេនឹងទៅជាយ៉ាងណាទៅ? កាលខ្ញុំនៅក្មេង ដោយសារ តែសង្គ្រាម

ទើបមិនបានរៀនសូត្រនឹងគេ ដល់ស្រុកមានសន្តិភាព មិនដឹងធ្វើការអីកើត មានតែធាក់ស៊ីក្លូរកលុយចិញ្ចឹមជីវិត រហូតមកដល់មានកូនក៏មិនដឹងធ្វើម៉េចទៀត មានតែទ្រាំរកស៊ីរបរហ្នឹងទៅ ដើម្បីកូន។ ឱជីវិតអើយ! ហេតុអ្វីក៏កម្សត់ម្ល៉េះ? ខ្ញុំលេបបាយលែងចូល ក្រោកដើរទៅក្នុងបន្ទប់។

- ឪវា! ឯងមានរឿងអី? (ប្រពន្ធខ្ញុំដើរចូលមកតាមសួរខ្ញុំ)

- មិនអីទេ!

- បើអត់អីទេ ម៉េចក៏មិនហូបបាយ?

- មិនឃ្លានទេ ឲ្យកូនហូបទៅ។ បានហើយ អស់កម្លាំងណាស់ ខ្ញុំត្រូវការសម្រាកបន្តិច។

ខ្ញុំយកខ្នើយមកគ្របមុខ ហើយប្រះខ្លួនលើគ្រែ។ ប្រពន្ធខ្ញុំមិននិយាយ ដើរចេញទៅក្រៅវិញ។ ខ្ញុំសញ្ជឹងគិតម្នាក់ឯង "គេមានប្រពន្ធ មានកូនដូចឯង គេមានឡានជិះ មានផ្ទះថ្មនៅ លុយចាយមិន អស់ ឯងឯងវិញ ផ្ទះមើលមិនយល់ ខោមិនខោ អាវមិនអាវ។ គេនៅតែស្មៀម លុយរត់មករក ឯងវិញ ខំរត់រកលុយចង់ងាប់ នៅមិនបានទៀត។ មនុស្សយើងកើតមក ម្ដេចក៏ខុសគ្នាអីចឹង... ខ្ញុំដក ដង្ហើមវែងៗបិទភ្នែកសំងំដេកបានមួយស្របក់ ក៏រៀបចំខ្លួនចេញទៅធាក់ស៊ីក្លូទៀត។

ពេញមួយថ្ងៃ បានម៉ូយបីនាក់ បានលុយតែបួនពាន់រៀលប៉ុណ្ណោះ។ អាសុខនៅតែមកខ្ចីលុយខ្ញុំ វាង៉ូចៗតាមខ្ចីដូចក្មេងទារបាយអីចឹងៈ

- អញប្រាប់ថាគ្មាន គឺគ្មានហើយ ថយចេញទៅ។ (ខ្ញុំស្រែកគំហកឲ្យវា)

- ឲ្យខ្ញុំសុំខ្ចីសិនម៉ោ តែប្រាំពាន់ទេពូ។

- អញអត់មានទេ។ អញរកបានតែបួនពាន់ ឲ្យអញទៅរកពីណា មួយពាន់ទៀតមកឲ្យអ្ហែង។ ទៅ! កុំមកខ្ចីអញទៀត ទៅរកអ្នកផ្សេងទៅ...

ខ្ញុំថាឲ្យវាប៉ុណ្ណឹងហើយ វានៅតែមិនព្រមឈប់តាមខ្ញុំ។ ខ្ញុំទ្រាំមិនបានក៏ធាក់ស៊ីក្លូត្រឡប់មកផ្ទះវិញ ព្រោះតែនៅទៀតប្រាកដជាទន់ចិត្តឲ្យវាខ្ចីមិនខាន។

យប់ស្ងាត់... ផ្ទះខ្ញុំមានតែពន្លឺអំពូលភ្លើងមួយ។ កូនៗដេកក្នុងមុងអស់ហើយ ឯប្រពន្ធខ្ញុំបក់ផ្លិតឲ្យកូន។ ខ្ញុំអង្គុយលើគ្រែមុខផ្ទះ សម្លឹងមើលលោកខែដែលរះតែមួយចំហៀង។

ប្រពន្ធរបស់ខ្ញុំចេញមកអង្គុយក្បែរ ហើយសួរៈ

- គិតអីទៀតហើយពុកវា?

- គ្មានស្អីទេ អត់ការងារធ្វើ អង្គុយគិតលេងៗទៅ!

- មីកាពៅវាក្អក ខ្ញុំចង់យកវាទៅឲ្យពេទ្យមើល...

- យកទៅ! ទៅ! កុំទុកកូនឲ្យឈឺយូរអី! (ខ្ញុំតបទៅប្រពន្ធកំបុតៗ)

- តែយើងគ្មានលុយទេ ខ្លាចមិនគ្រប់ថ្លៃពេទ្យ។

- ទៅយកក្នុងហោប៉ៅទៅ...! យកទៅមើលជំងឺកូនទៅ។

ខ្ញុំចេញពីផ្ទះតាំងពីព្រលឹម ដឹកប្រពន្ធនិងកូនដាក់នៅពេទ្យ ហើយបង្ហួសមកផ្សារ។ ខ្ញុំចតស៊ីក្លូនៅកន្លែងដែលធ្លាប់ចត រួចដើរចូលទៅរកគ្នារបស់ខ្ញុំ។ អាសុខ អាម៉ៅ និងអាផលកំពុងឈរជជែកគ្នា មើលទៅពួកវាដូចជាមានរឿងអីសំខាន់កំពុងពិភាក្សា។ ខ្ញុំដើរចូលទៅជិតហើយសួរពួកវាៈ

- ពួកអ្ហែងមានរឿងអី បានជាឈរខ្សឹបខ្សៀវគ្នាហ្នឹង?

- គ្មានរឿងស្អីទេ! ថ្ងៃនេះមកពីព្រលឹមម្ល៉េះ? (អាផលសួរ)

- ដឹកកូនទៅពេទ្យ ហើយឆ្លៀតមកបណ្ដោយទៅ។

- កូនអ្ហែងកើតអី?

- ផ្ដាសាយ ក្អក.... ហើយពួកអ្ហែងមានរឿងអី?

- មានអី... ម្សិលមិញទៅវត្ត មានលោកមួយអង្គ គេល្បីថាពូកែ ឲ្យលេខឆ្នោតក៏ពូកែដែរ។ អញទៅរកលោក លោកក៏ឲ្យលេខឆ្នោត។ អាសុខវាប្រាប់ថា
យប់មិញវាយល់សប្តិឃើញលេខម្ភៃប្រាំ ហើយលេខដែលលោកឲ្យនោះក៏ម្ភៃប្រាំដែរ។

- វាមិនដែលជួនគ្នាដល់ម្លឹងទេ អា្នា (ខ្ញុំពេបមាត់ដាក់វា)

- ជួនកាលវាអាចដែរពូ។ មនុស្សយើងសំណាងមើលមិនឃើញទេ។ (អាមៅឆ្លើយ)

- អើ! ហើយអ្អែងគិតយ៉ាងម៉េច? (ខ្ញុំសួរ)

- កំពុងតែគិត មិនដឹងថាត្រូវចាក់ប៉ុន្មាន? (អាមៅឆ្លើយ)

- អើ! គិតមើលទៅ ប៉ុន្តែអញប្រាប់ កុំជឿតាមយល់សប្តិពេក ប្រយ័ត្នអស់គូថខោវ៉ើយ...

ខ្ញុំនិយាយបានតែប៉ុណ្ណឹងព្រោះមានម៉ូយមករកជិះស៊ីក្លូ ខ្ញុំក៏ប្រញាប់ទៅទទួល។ ពេលខ្ញុំត្រឡប់ពីដឹកម៉ូយ បាត់ពួកវាអស់។ ខ្ញុំសង្ស័យថា ប្រាកដជាទៅចាក់ឆ្នោតហើយ។
តាមពិតពួកយើង ទាំងអស់គ្នាសុទ្ធតែដឹងថា ការផ្សងសំណាងបែបនេះគឺមិនងាយទេ
តែយើងមិនដឹង ធ្វើម៉េចទើបមាន ប្រាក់ បានជាយើងពឹងលើផ្លូវមួយនេះ។
ខ្ញុំក៏ធ្លាប់លេងឆ្នោតដែរតែយូរៗលេងម្តង ដល់ខ្ញុំគិតមើល ទៅឃើញថាគ្មានប្រយោជន៍ក៏ឈប់លេង។

...ថ្ងៃនេះរកបានប្រាក់ច្រើនគួរសម ខ្ញុំត្រឡប់ទៅផ្ទះពីព្រលប់។ ទៅដល់ផ្ទះ ប្រពន្ធខ្ញុំប្រាប់ថាត្រូវទិញថ្នាំឲ្យកូនទៀត ខ្ញុំយកលុយដែលរកបានឲ្យទៅប្រពន្ធយកទៅទិញថ្នាំ។

ព្រលឹមឡើង ខ្ញុំមកដល់ផ្សារ ឃើញពួកវាទាំងបី ខ្ញុំក៏សួរះ

- យ៉ាងម៉េចហើយអា្នា? ឆ្នោតចេញលេខប៉ុន្មាន?

- ចង្រៃដល់ហើយ ចាក់ម្ភៃប្រាំចេញម្ភៃប្រាំមួយ ក្តៅមែនទែន។

អាសុខវាស្រែកឡើង។ ខ្ញុំសើច រួចនិយាយចំអកឲ្យវាះ

- អាហ្នឹងហើយលោកល្បី ឲ្យលេខឆុតណាស់ ឥឡូវម៉េចដែរ?

- ខ្ញុំពីរនាក់អាម៉ៅមិនសូវអីប៉ុន្មានទេ តែពូផលគាត់យកលុយសម្រាប់បង់ថ្លៃផ្ទះទៅចាក់អស់ហើយ ឥឡូវមិនដឹងរកពីណាឲ្យគេទេ។

- ដល់ម្លឹងផងអាផល? យីអានេះគ្មានកំណើតមែន! (ខ្ញុំងាកមកបន្ទោសអាផល)

អាផលមិនមាត់មិនក វាងាកមុខចេញ។ ខ្ញុំមិនដឹងជាត្រូវនិយាយអីទៀត ក៏ដើរមកឈរក្បែរស៊ីក្លូចាំម៉ូយមកជិះវិញ។ ខ្ញុំមិនហ៊ានសួរនាំអីទៀតទេ។ ការពិតខ្ញុំដឹងរឿងនេះយូរហើយ។ ល្ងាចមិញ ខ្ញុំឃើញឆ្នោតចេញលេខម្ភៃប្រាំមួយ ខ្ញុំដឹងថាពួកវាចាញ់ហើយ។ ខ្ញុំធ្វើដូចគ្រាន់បើ តែតាមពិតខ្ញុំក៏ លួចចាក់ដែរ។ នេះហើយក្រ។

ស្អែកឡើងអត់ឃើញអាផលមកធាក់ស៊ីក្លូសោះ ខ្ញុំមិនបានចាប់អារម្មណ៍នឹងរឿងដែលវាបាត់ទេ។ រសៀលបន្តិច ខ្ញុំត្រលប់ពីផ្ទះមកផ្សារវិញ។
អាម៉ៅនិងអាសុខពេលឃើញខ្ញុំក៏និយាយឡើង៖

- ពូៗ ពូដឹងទេ? ពូផលត្រូវឡានបុកហើយ។

ខ្ញុំភ្ញាក់ព្រើត សួរទៅវិញថា៖

- វាយ៉ាងម៉េចហើយ? ម៉េចបានជាអីចឹង?

- គាត់ចាញ់ឆ្នោត អត់មានលុយឲ្យថ្លៃផ្ទះគេ អីចឹងគាត់ខំធាក់ស៊ីក្លូពេលយប់។ យប់មិញនេះ អាឡានមួយនោះ ម្ចាស់វាស្រវឹងស្រា កៀរគាត់ ឥឡូវឮថាដេកពេទ្យ។

- ចុះម៉េចបានជាពួកអ្អែងដឹង?

- យាយលក់បន្លែដែលនៅក្បែរផ្ទះពូផលនិយាយ។

- អាចស្លាប់ទេអ្ហ៎?

- របួសតិចតួច ឮថាមិនអីទេ!

- ហ្នឹងហើយល្បែង។ ចាំមើល តើវារាងឬអត់?

ខ្ញុំមកគិតម្នាក់ឯងថាៈ "ព្រះអើយ! មិនដឹងថាយ៉ាងម៉េចទៅហើយទេ លុយថ្លៃជួលផ្ទះគ្មានបង់ឲ្យគេ ខ្លួនក៏មានរបួសទៀត ប្រពន្ធគ្មានរបរ ឯកូនក៏នៅតូចៗ ធ្វើអីកើត! តើជីវិតវានឹងទៅជាយ៉ាង ណា?″

ខ្ញុំងាកមកគិតពីខ្លួនឯងវិញ...បើថ្ងៃណាមួយ ខ្ញុំមិននៅក្បែរប្រពន្ធ តើប្រពន្ធនិងកូនទាំងប្រាំរបស់ខ្ញុំរស់បែបណា? ខ្ញុំពិបាកចិត្តខ្លាំងណាស់។ មានពាក្យមួយថា "ធ្វើមនុស្សត្រូវតែមានសង្ឃឹម... ត្រូវតែប្រឹងតស៊ូ ថ្ងៃណាមួយគង់តែសម្រេចមិនខាន"។ តែខ្ញុំតស៊ូច្រើនឆ្នាំហើយ គ្មានឃើញអ្វីប្រែ ប្រួលសោះ។ ក្រនៅតែក្រ...មិនដឹងសង្ឃឹមអ្វីទេ។ ខ្ញុំរកផ្លូវសម្រាប់ជីវិតមិនឃើញឡើយ។

អាផលត្រឡប់មកធាក់ស៊ីក្លូវិញហើយ។ ទឹកមុខវាស្លេកស្លាំង។ ខ្ញុំសួរនាំពីស្ថានភាពរបស់វា វាថា"ម្ចាស់ផ្ទះឲ្យវាជំពាក់ តែខែក្រោយត្រូវសងទាំងអស់ បើមិនអ៊ីចឹងទេ គេឈប់ជួលផ្ទះឲ្យវាទៀត ហើយ"។ ខ្ញុំសម្លឹងមើលវា ដោយក្តីអាណិតអាសូរមែនទែន តែមិនដឹងជួយវាតាមវិធីណាបើខ្ញុំអត់ ដែរ។ ខ្ញុំប្រឹងរកស៊ី មិនហ៊ានឈប់ ដល់ពេលបាយខ្ញុំហៅអាផលឲ្យទៅបាយជាមួយខ្ញុំ។

ថ្ងៃនេះ ខ្ញុំត្រឡប់មកផ្ទះវិញលឿនជាងសព្វដង ព្រោះកូនខ្ញុំឈឺ។ ខ្ញុំប្រញាប់ដឹកកូនទៅពេទ្យ។ ខ្ញុំទៅដល់មន្ទីរពេទ្យ ខ្ញុំតូចចិត្តណាស់។ ព្រោះតែខ្ញុំក្រ ខំស្វះស្វែងរកពេទ្យមកមើលកូន ប៉ុន្តែពេទ្យ អស់ទាំងនោះ មិនរវល់មើលទេ គេទុកឲ្យខ្ញុំនិងប្រពន្ធចាំជិតកន្លះថ្ងៃ។ គេថាពេទ្យជាអ្នកសង្គ្រោះជីវិត មនុស្ស តែខ្ញុំមើលទៅមិនដូចសោះ។ ឯពេទ្យដែលធ្វើការនៅទីនោះ សម្តីអាក្រក់ណាស់ ឃើញយើង ស្រេៗ ចូលទៅ ចង់សួរនាំអីក៏ពិបាកដែរ។

ខ្ញុំកាន់តែគិត កាន់តែពិបាក មិនដឹងថា ថ្ងៃណាខ្ញុំអាចរួចផុតពីទុក្ខលំបាកនោះទេ។ ខ្ញុំមើលទៅថ្នល់ ឃើញក្មេងៗ មានម៉ូតូ ឡានជិះ ខ្ញុំស្ទើចណាស់។ ពួកគេកើតមក ចំពេលស្រុកអស់សង្គ្រាម កើតមកមានឪពុកម្តាយ ជាអ្នកមានស្តុកស្តម្ភ ពួកគេមិនដែលភ័យ ពីរឿងអត់លុយនោះទេ។ អាផល ឃើញខ្ញុំអង្គុយម្នាក់ឯងក៏ដើរមកជិតមកហើយសួរនាំៈ

- កូនអ្អែងយ៉ាងម៉េចហើយ?
- គ្រាន់បើជាងមុន...

- ពេទ្យគេថាម៉េច?

- គេឲ្យលេបថ្នាំ (ខ្ញុំអួលដើមក និយាយមិនចេញ)។ អាផលទះស្មាខ្ញុំតិចៗ ហើយនិយាយថា៖

- កុំតូចចិត្តអី! ទ្រាំៗទៅ។

- អញឆ្ងល់ណាស់ គេថា តស៊ូនៅទីណា សម្រេចនៅទីនោះ ចុះអញ? ខំតស៊ូអស់ច្រើនឆ្នាំហើយ ម៉េចក៏មិនឃើញសម្រេចអីសោះ? ក្រោយពីធ្វើជាទាហាន អញធាក់ស៊ីក្លូមកដល់ឥឡូវហើយ អនាគត មើលទៅអញនៅតែធាក់ស៊ីក្លូដដែល។ អាហ្នឹងអ្អែស ដែលថាតស៊ូបានសម្រេច?

- គិតអីឆ្ងាយម្ល៉េះ? អ្អែងដឹងទេ ព្រះពុទ្ធថាមនុស្សយើង កើតមកមានកម្មតាមមកជាមួយ ហេតុតែយើងកើតមកជាអ្នកក្រ ដោយសារតែយើងធ្វើកម្មពីជាតិមុន អីចឹងយើងត្រូវព្រមទទួលកម្ម ហ្នឹងទៅ។ ទ្រាំៗទៅអាជឿនអើយ! ក្រែងពេលកូនៗធំមានបុណ្យ ក្លាយជាអ្នកមាន យើងលែង លំបាកទៀតហើយ។

ខ្ញុំស្តាប់សម្តីអាផល វានិយាយពីរឿងកូន។ កូនរបស់ខ្ញុំប្រាំនាក់ អាបងបង្អស់ទើបតែអាយុប្រាំបួនឆ្នាំ ឯខ្ញុំអាយុសែប្លាយហើយ ទម្រាំដល់វាធំនោះ ខ្ញុំប្រហែលជាធ្វើស្នូលដីទៅហើយ តើមាន ពេលចាយលុយកូនទេ? ទេវតាអើយទេវតា តើលោកឃើញទុក្ខខ្ញុំទេ? ម្តេចលោកមិនជួយ? តើលោក ចង់ឲ្យពួកយើងស្លាប់អស់ ទើបលោកយាងមកប្រោសមែនទេ?

- មិនមែនតែឯងទេ មានអញនិងខ្មែរច្រើននាក់ទៀតដែលរងទុក្ខ។

អាផលនិយាយហើយដើរចេញទៅព្រោះមានគេមករកជិះស៊ីក្លូ ខ្ញុំឯណោះក៏មានម៉ូយដែរ។

- ទៅសាលាសន្ធរម៉ុក យកប៉ុន្មាន? (ស្រ្តីចំណាស់ម្នាក់សួរខ្ញុំ)

- ពីរពាន់អ៊ំ!

- ថ្លៃណាស់ មួយពាន់បានហើយ...

- ចម្ងាយពីផ្សារដេប៉ូទៅដល់សន្ទរម៉ុក ប៉ុណ្ណឹងមិនថ្លៃទេ!

... ដឹកម៉ូយដល់សន្ទរម៉ុកហើយ ខ្ញុំក៏លើកដៃបត់ស៊ីក្លូត្រឡប់មកវិញ។ ពេលខ្ញុំបត់មកដល់ពាក់កណ្តាលថ្នល់ ស្រាប់តែផាំង...! ខ្លួនខ្ញុំប៉ើងចេញពីស៊ីក្លូទៅលើចិញ្ចើមថ្នល់។ មនុស្សម្នាផ្អើល ឈូឆរមកមើល។ សម្លេងអ៊ូអរលាន់ឮពេញត្រចៀកខ្ញុំ៖

- យី! គាត់យ៉ាងម៉េចហើយ? ជួយមើលគាត់ផង។

- មានរឿងអីហ្នឹង? អ្នកណាបុក?

- អាឡានឡង់គ្រីស័រនោះ ឥឡូវបើករត់បាត់ហើយ។

- តេហៅឡានពេទ្យមក។ ជួយគាត់យកតែបុណ្យទៅ លឿនឡើង ឈាមហូរច្រើនណាស់។

ខ្ញុំប្រឹងបើកភ្នែកមើលអ្នកនៅជុំវិញ ខ្ញុំមើលឃើញយ៉ាងច្បាស់ ហើយពន្លឺចាប់ផ្តើមរលត់បន្តិចម្តងៗ...៕